# ការអនុវត្តន៍ល្អ
## កម្មវិធីលើកទឹកចិត្ត

រោងចក្រកាន់តែប្រសើរ នៅកម្ពុជា

កម្មវិធីលើកទឹកចិត្ត (ឬកម្មវិធីផ្តល់រង្វាន់) អាចជាវិធីសាស្ត្រមួយយ៉ាងមានប្រសិទ្ធភាព ដើម្បីលើកកំពស់ការបំពេញការងាររបស់កម្មករ និងធ្វើអោយកម្មករពេញចិត្តចំពោះការងារ ។ មានប្រភេទការលើកទឹកចិត្តជាច្រើន ចាប់ពីការនិយាយពាក្យសរសើរធម្មតា រហូតដល់ការផ្តល់រង្វាន់ជាថវិកា ។ ការសិក្សាជាច្រើនបង្ហាញថា កម្មវិធីលើកទឹកចិត្តដែលល្អ បង្កើនការលើកទឹកចិត្ត បង្កើនភាពសប្បាយរីករាយ និងលើកកំពស់ការអនុវត្តន៍ការងារ។ បើនិយាយពីក្រុមហ៊ុនវិញ កម្មវិធីលើកទឹកចិត្ត តែងតែមានភាពងាយស្រួល និងមានផលចំណេញច្រើនក្នុងការអនុវត្តន៍ការងារ ។

### *ការអនុវត្តន៍ល្អសំរាប់កម្មវិធីលើកទឹកចិត្តកម្មករ*

**ការលើកទឹកចិត្តជាក្រុម** បង្ហាញការបំពេញការងារផលិតកម្មសំរាប់ក្រុម ដែលធ្វើការល្អបំផុតក្នុងខែនីមួយៗ។ ធានាយ៉ាងណា អោយមានភាពងាយស្រួល ដើម្បីដឹងថាក្រុមណាដែលធ្វើល្អបំផុត និងកំរិតសមត្ថភាពរបស់ពួកគេ (រូបភាពទី១) ។

**ការលើកទឹកចិត្តសំរាប់ម្នាក់ៗ** ទទួលស្គាល់ការបំពេញការងារបានល្អ តាមរយៈការផ្តល់ប័ណ្ណសរសើរចំពោះកម្មករដែលបំពេញការងារបានល្អ ។ ដាក់តាំងបង្ហាញប័ណ្ណសរសើរនៅក្នុងបន្ទប់ដាក់តាំងផលិតផល (រូបភាពទី២) ។

**ការលើកទឹកចិត្តជាក្រុម** ផ្តល់រង្វាន់ជាថវិកា ឬក៏ផលប្រយោជន៍ផ្សេងទៀត (ដូចជារង្វាន់ ឬសំបុត្រកុន) អោយដល់ក្រុមកម្មករនៅពេលដែលក្រុមនេះបានសំរេចគោលដៅការងារ (រូបភាពទី៣) ។

**ការលើកទឹកចិត្តសំរាប់ម្នាក់ៗ** ផ្តល់រង្វាន់ជាសាច់ប្រាក់ ឬផលប្រយោជន៍ដទៃទៀត សំរាប់ការបំពេញការងារបានល្អ ។



រូបភាពទី១



រូបភាពទី២



រូបភាពទី៣

### អត្ថប្រយោជន៍:

- ✓ លើកកំពស់ផលិតភាព
- ✓ ផ្សារភ្ជាប់ការបំពេញការងាររបស់កម្មករជាមួយនឹងគោលដៅរបស់រោងចក្រ
- ✓ លើកកំពស់ភាពពេញចិត្តជាមួយការងារ

### តាមរបៀបណា:

- ✓ រៀបចំដោយអ្នកគ្រប់គ្រងរោងចក្រ

### តំលៃ:

**$**

- $ តំលៃទាប
- $$ តំលៃមធ្យម
- $$$ តំលៃខ្ពស់